**The School District of Philadelphia**
Office of Student Rights & Responsibilities
440 N. Broad Street, Second Floor
Philadelphia, PA 19130
Office: 215.400.4830 ~ Fax: 215.400.4226

Rachel Holzman, Esquire
អនុប្រធាន

## ការផ្តល់ដំណឹងអំពីសិទ្ធិផ្សេងៗ ក្រោមច្បាប់ FERPA សម្រាប់ សាលាបឋមសិក្សា និងវិទ្យាល័យ

សិទ្ធិនៃការសិក្សា និងច្បាប់រក្សាការសម្ងាត់ របស់ក្រុមគ្រួសារ - The Family Educational Rights and Privacy Act (FERPA) ផ្តល់សិទ្ធិដល់មាតាបិតា និងសិស្សានុសិស្សណាដែលមានអាយុ ១៨ ឆ្នាំឡើងទៅ («សិស្សានុសិស្សដែលមានសិទ្ធិ») នូវសិទ្ធិដែលទាក់ទងនឹងឯកសារសិក្សាផ្សេងៗរបស់សិស្ស។ សិទ្ធិទាំងនេះរួមមាន៖

1. សិទ្ធិពិនិត្យ និងពិនិត្យឡើងវិញនូវឯកសារសិក្សារបស់សិស្ស ក្នុងអំឡុងពេល ៤៥ ថ្ងៃ ក្រោយថ្ងៃដែលសាលាទទួលសំណើសុំពិនិត្យឯកសារ។

   មាតាបិតា ឬសិស្សានុសិស្សដែលមានសិទ្ធិ ដែលមានបំណងចង់ពិនិត្យមើលឯកសារ ឬឯកសារសិក្សារបស់កូនគាត់ គប្បីដាក់ពាក្យស្នើទៅនាយកសាលា តាមការសរសេរជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ពីឯកសារដែលគាត់ចង់ពិនិត្យមើល។ ភ្នាក់ងារសាលានឹងធ្វើការរៀបចំឱ្យមានការពិនិត្យមើល និងផ្តល់ដំណឹងទៅមាតាបិតា ឬសិស្សដែលមានសិទ្ធិ អំពីពេលវេលា និងទីកន្លែង ដែលអាចពិនិត្យមើលឯកសារទាំងនេះ។

2. សិទ្ធិស្នើសុំឲ្យមានការកែប្រែឯកសារសិក្សារបស់សិស្ស ដែលមាតាបិតា ឬសិស្សដែលមានសិទ្ធិ ជឿថាមានការខុសឆ្គង បំភ័ន្ត ឬបើមិនដូច្នោះបំពានលើសិទ្ធិនៃការរក្សាទុកជាសម្ងាត់របស់សិស្ស ក្រោមច្បាប់ FERPA ។

   មាតាបិតា ឬសិស្សានុសិស្សដែលមានសិទ្ធិ ដែលមានបំណងស្នើសុំឱ្យសាលាធ្វើការកែប្រែឯកសារ ឬឯកសារសិក្សារបស់កូន គប្បីទាក់ទងទៅនាយកសាលា ឬភ្នាក់ងារសាលាណាម្នាក់ តាមការសរសេរជាលាយលក្ខណ៍អក្សរ បញ្ជាក់ឲ្យបានច្បាស់លាស់នូវជំពូកនៃឯកសារដែលពួកគេចង់ឲ្យកែប្រែ ហើយបញ្ជាក់ពីមូលហេតុដែលត្រូវផ្លាស់ប្តូរ។ ប្រសិនបើសាលាសម្រេចថាមិនកែប្រែឯកសារតាមការស្នើសុំរបស់មាតាបិតា ឬសិស្សដែលមានសិទ្ធិទេនោះ សាលានឹងជម្រាបទៅ មាតាបិតា ឬសិស្សដែលមានសិទ្ធិ នូវការសម្រេចនេះ និងសិទ្ធិរបស់ពួកគេក្នុងការតវ៉ាដែលទាក់ទងនឹងការស្នើសុំឲ្យមានការកែប្រែនេះ។ ព័ត៌មានបន្ថែមទាក់ទងនឹងនីតិវិធីសវនាការ នឹងត្រូវបានផ្តល់ជូនដល់មាតាបិតា ឬសិស្សដែលមានសិទ្ធិនៅពេលជូនដំណឹងអំពីសិទ្ធិទៅកាន់សវនាការ។

3. សិទ្ធិផ្តល់ការយល់ព្រមតាមការសរសេរជាលាយលក្ខណ៍អក្សរ មុនពេលសាលាបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលអាចកត់សម្គាល់បាន (PII) ពីឯកសារសិក្សារបស់សិស្ស លើកលែងតែក្នុងករណីណាដែលច្បាប់ FERPA អនុញ្ញាតឱ្យបញ្ចេញ ដោយមិនចាំបាច់មានការយល់ព្រម។

   មានករណីលើកលែងមួយដែលគេអនុញ្ញាតឱ្យបញ្ចេញព័ត៌មានដោយមិនចាំបាច់មានការយល់ព្រម គឺការផ្តល់ព័ត៌

មានដល់ភ្នាក់ងារសាលាដែលទាក់ទងដល់ការអប់រំដែលត្រឹមត្រូវតាមច្បាប់។ លក្ខណៈវិនិច្ឆ័យនៃការសម្រេចថាតើនរណារាប់ថាជាភ្នាក់ងារសាលា ហើយអ្វីទៅដែលគិតថាជាការអប់រំស្របច្បាប់ ត្រូវមាននៅក្នុងការផ្តល់ដំណឹងប្រចាំឆ្នាំរបស់សាលា ឬក្រសួងអប់រំ សម្រាប់សិទ្ធិនៃច្បាប់ FERPA។ ភ្នាក់ងារសាលា តាមធម្មតារួមមាន អ្នកដែលសាលា ឬក្រសួងអប់រំជួលឲ្យធ្វើការ ជាអភិបាល អ្នកដឹកនាំ គ្រូបង្ហាត់បង្រៀន ឬសមាជិកនៃបុគ្គលិកជំនួយការ (រួមមាន បុគ្គលិកផ្នែក សុខភាព ឬសុខាភិបាល និងភ្នាក់ងារខាងអាជ្ញាធរ សម្រាប់សុខភាព និង/ឬ មូលហេតុនៃសុវត្ថិភាព ឬក្នុងការឆ្លើយតបទៅនឹងបញ្ហាតុលាការ ឬដីកា) ឬអ្នកដែលបម្រើក្នុងគណកម្មាធិការនៃក្រសួងអប់រំ។ ភ្នាក់ងារសាលាក៏អាចរាប់បញ្ចូល អ្នកស្ម័គ្រចិត្ត អ្នកម៉ៅការ ឬអ្នកពិគ្រោះយោបល់ ដែលសាលាមិនមែនជាអ្នកជួល ដើម្បីបំពេញមុខងារដល់ស្ថាប័ន ឬមុខងារដែលសាលាមិនបាច់ប្រើបុគ្គលិកផ្ទាល់ ហើយជាអ្នកដែលនៅក្រោមការត្រួតត្រាផ្ទាល់របស់សាលា ចំពោះការប្រើ និងរក្សា ព័ត៌មានផ្ទាល់ខ្លួនដែលអាចកត់សម្គាល់បាន (PII) ពីឯកសារសិក្សា ដូចជា មេធាវី អ្នកត្រួតត្រាបញ្ជី ទីប្រឹក្សាផ្នែកសុខាភិបាល ឬអ្នកព្យាបាល។ មាតាបិតា ឬសិស្សស្ម័គ្រចិត្តជាគណៈកម្មការផ្លូវការ ដូចជាគណៈកម្មការផ្នែក ដាក់វិន័យ ឬទទួលបណ្តឹង។ មាតាបិតា សិស្ស ឬអ្នកស្ម័គ្រចិត្តផ្សេងទៀតដែលជួយភ្នាក់ងារសាលាក្នុងការបំពេញភារកិច្ចរបស់គាត់។ បុគ្គលិកសាលា តាមធម្មតាមានមូលហេតុត្រឹមត្រូវ ប្រសិនបើពួកគាត់ត្រូវពិនិត្យឲ្យបានហ្មត់ចត់នូវឯកសារសិក្សា ដើម្បីបំពេញនូវការទទួលខុសត្រូវលើកិច្ចការងាររបស់ពួកគាត់។ ជាធម្មតា ភ្នាក់ងារសាលាមានចំណាប់អារម្មណ៍ផ្នែកអប់រំស្របច្បាប់ ប្រសិនបើមានការត្រូវការពិនិត្យឯកសារអប់រំឡើងវិញជាផ្លូវការ ដើម្បីបំពេញទំនួលខុសត្រូវនៃវិជ្ជាជីវៈរបស់គាត់។

បើមានការស្នើសុំ សាលានឹងបញ្ចេញឯកសារសិក្សាដោយមិនចាំបាច់មានការយល់ព្រម ឲ្យទៅភ្នាក់ងារសាលា ឬក្រសួងអប់រំដទៃទៀត ដែលសិស្សប្រាថ្នា ឬមានបំណងចង់ចុះឈ្មោះរៀន ឬចុះឈ្មោះរួចហើយ ប្រសិនបើការបញ្ចេញព័ត៌មាននេះសម្រាប់គោលបំណងនៃការចុះឈ្មោះ ឬការផ្លាស់ប្តូររបស់សិស្ស។

4. សិទ្ធិដាក់បណ្តឹងទៅ ក្រសួងអប់រំប្រចាំសហរដ្ឋ (U.S. Department of Education) ដែលទាក់ទងនឹងការមិនអនុវត្តតាមតម្រូវការនៃច្បាប់ FERPA ដោយក្រសួងអប់រំ។ ឈ្មោះ និងអាសយដ្ឋាន របស់ការិយាល័យចាត់ចែងច្បាប់ FERPA គឺ៖

    Student Privacy Policy Office
    U.S. Department of Education
    400 Maryland Avenue, SW
    Washington, DC 20202

FERPA អនុញ្ញាតឱ្យបញ្ចេញព័ត៌មានផ្ទាល់ខ្លួនដែលអាចកត់សម្គាល់បាន (PII) ពីឯកសារសិក្សារបស់សិស្ស ដោយមិនចាំបាច់មានការយល់ព្រមពីមាតាបិតា ឬសិស្សដែលមានសិទ្ធិ ប្រសិនបើការបញ្ចេញនេះត្រូវតាមល័ក្ខខ័ណ្ឌជាក់លាក់ដែលមាននៅក្នុងមាត្រា § 99.31 នៃបទបញ្ញត្តិ FERPA។ លើកលែងតែការបញ្ចេញព័ត៌មានទៅឲ្យភ្នាក់ងារសាលា ការបញ្ចេញព័ត៌មានដែលទាក់ទងនឹងដីកាតុលាការ ឬដីកាកោះដែលបានចេញស្របច្បាប់ ការបញ្ចេញព័ត៌មានដែលមិនបណ្តាលឲ្យមានគ្រោះថ្នាក់ និងការបញ្ចេញព័ត៌មានទៅឲ្យមាតាបិតា ឬសិស្សដែលមានសិទ្ធិ មាត្រា § 99.32 នៃបទប្បញ្ញត្តិ FERPA តម្រូវឱ្យសាលាកត់ត្រាការបញ្ចេញព័ត៌មាននេះ។ មាតាបិតា និងសិស្សដែលមានសិទ្ធិ មានសិទ្ធិពិនិត្យមើល និងពិនិត្យឡើងវិញនូវឯកសារដែលត្រូវបញ្ចេញ។ សាលាអាចបញ្ចេញព័ត៌មាន PII ពីឯកសារសិក្សារបស់សិស្ស ដោយមិនចាំបាច់មានការយល់ព្រមតាមការសរសេរជាលាយលក្ខណ៍អក្សរជាមុនពីមាតាបិតា ឬសិស្សដែលមានសិទ្ធិ –

- ឲ្យទៅភ្នាក់ងារសាលាផ្សេងៗ រួមទាំងគ្រូបង្រៀន នៅក្នុងភ្នាក់ងារ ឬស្ថាប័នអប់រំដែលសាលាបានសម្រេចថាត្រឹមត្រូវសម្រាប់ការអប់រំស្របច្បាប់។ នេះរួមមាន អ្នកម៉ៅការ អ្នកពិគ្រោះយោបល់ អ្នកស្ម័គ្រចិត្ត ឬភាគីផ្សេងទៀតដែលសាលាបានផ្តល់កិច្ចការ ឬមុខងារ តាមល័ក្ខខ័ណ្ឌដែលមាននៅក្នុងច្បាប់ § 99.31(a)(1)(i)(B)(*1*) – (a)(1)(i)(B)(*3*) ដែលត្រូវតាមតម្រូវការ។ (§ 99.31(a)(1))។

- ឲ្យទៅភ្នាក់ងារនៃសាលាផ្សេងៗ ប្រព័ន្ធសាលា ឬស្ថាប័នអប់រំជាន់ខ្ពស់ ដែលសិស្សស្វែងរក ឬមានបំណងចុះឈ្មោះ ឬកន្លែងដែលសិស្សបានចុះឈ្មោះរួចហើយ ប្រសិនបើការបញ្ចេញព័ត៌មាននេះមានគោលបំណងដែលទាក់ទងនឹងការចុះឈ្មោះ ឬការផ្លាស់ប្តូររបស់សិស្ស ទៅតាមតម្រូវការនៃច្បាប់ § 99.34។ (§ 99.31(a)(2))។

- ឲ្យទៅអ្នកតំណាងនៃ នាយកការិយាល័យទទួលខុសត្រូវប្រចាំសហរដ្ឋ (U.S. Comptroller General) អគ្គមេធាវីប្រចាំសហរដ្ឋ (U.S. Attorney General) លេខាធិការក្រសួងអប់រំប្រចាំសហរដ្ឋ (U.S. Secretary of Education) ឬ អាជ្ញាធរខាងអប់រំ ក្នុងតំបន់ ឬរដ្ឋ ដូចជា ទីភ្នាក់ងារអប់រំប្រចាំរដ្ឋ [State Educational Agency (SEA)] ក្នុងរដ្ឋរបស់មាតាបិតា ឬសិស្សដែលមានសិទ្ធិ។ ការបញ្ចេញព័ត៌មានតាមបទប្បញ្ញត្តិនេះអាចធ្វើឡើងឲ្យស្របទៅតាមតម្រូវការនៃច្បាប់ § 99.35 ដែលទាក់ទងនឹងការត្រួតពិនិត្យបញ្ជី ឬការវាយតម្លៃ របស់រដ្ឋសហព័ន្ធ- ឬកម្មវិធីអប់រំដែលគាំទ្រដោយរដ្ឋ ឬសម្រាប់ការតម្រូវឲ្យអនុវត្ត ឬអនុលោមតាមតម្រូវការច្បាប់រដ្ឋសហព័ន្ធ ដែលពាក់ព័ន្ធនឹងកម្មវិធីទាំងនោះ។ ស្ថាប័នទាំងនេះអាចបញ្ចេញព័ត៌មាន PII ថែមទៀត ទៅឲ្យស្ថាប័ននៅក្រៅ ដែលបានរៀបចំដោយពួកគេ ជាអ្នកតំណាងដែលមានការអនុញ្ញាតរបស់ពួកគេ ដើម្បីសកម្មភាពនៃការត្រួតពិនិត្យបញ្ជី វាយតម្លៃ ឬតម្រូវឲ្យអនុវត្ត ឬអនុលោមតាម ក្នុងនាមរបស់ពួកគេ ប្រសិនបើធ្វើតាមតម្រូវការដែលពាក់ព័ន្ធទាំងអស់។ (§ 99.31(a)(3) and 99.35)។

- ទាក់ទងនឹងជំនួយហិរញ្ញវត្ថុ (financial aid) ដែលសិស្សបានដាក់ពាក្យសុំ ដែលសិស្សបានទទួល ប្រសិនបើចាំបាច់ត្រូវមានព័ត៌មាននេះ សម្រាប់គោលបំណងដើម្បីសម្រេចសិទ្ធិទទួលជំនួយ កំណត់ចំនួននៃជំនួយ កំណត់ល័ក្ខខ័ណ្ឌនៃជំនួយ ឬតម្រូវឲ្យធ្វើតាមល័ក្ខខ័ណ្ឌនៃជំនួយ។ (§ 99.31(a)(4))។

- ឲ្យទៅភ្នាក់ងារថ្នាក់រដ្ឋ និងក្នុងតំបន់ ឬអាជ្ញាធរ ដែលព័ត៌មាននេះត្រូវបានគេអនុញ្ញាតឱ្យរាយការណ៍ ឬបញ្ចេញ តាមលក្ខន្តិកៈរបស់រដ្ឋ ដែលទាក់ទងនឹងប្រព័ន្ធយុត្តិធម៌យុវវ័យ និងសមត្ថភាពនៃប្រព័ន្ធក្នុងការបម្រើឲ្យមានប្រសិទ្ធិភាពសម្រាប់សិស្សដែលត្រូវបញ្ចេញឯកសាររបស់ពួកគេ មុនពេលធ្វើការវិនិច្ឆ័យ តាមច្បាប់ § 99.38។ (§ 99.31(a)(5))។

- ឲ្យទៅអង្គការដែលធ្វើការសិក្សា សម្រាប់ ឬក្នុងនាមនៃសាលា ដើម្បី៖ (a) អភិវឌ្ឍ ធ្វើឱ្យមានសុពលភាព ឬចាត់ចែងការធ្វើតេស្តសាកល្បង (b) ចាត់ចែងកម្មវិធីជួយដល់សិស្ស ឬ (c) កែលម្អការបង្ហាត់បង្រៀន ប្រសិនបើធ្វើតាមតម្រូវការដែលពាក់ព័ន្ធទាំងអស់។ (§ 99.31(a)(6))។

- ផ្តល់ការទទួលស្គាល់ស្ថាប័នជាផ្លូវការ ដើម្បីអនុវត្តមុខងារទទួលស្គាល់របស់ពួកគេ។ (§ 99.31(a)(7))។

- ឲ្យទៅមាតាបិតារបស់សិស្សដែលមានសិទ្ធិ ប្រសិនបើសិស្សពឹងផ្អែកលើមាតាបិតា សម្រាប់គោលបំណងនៃ ពន្ធ IRS (IRS tax)។ (§ 99.31(a)(8))។

- ដើម្បីធ្វើតាមបញ្ជាតុលាការ ឬដីកាដែលបានចេញតាមច្បាប់ ប្រសិនបើធ្វើតាមតម្រូវការដែលពាក់ព័ន្ធទាំងអស់។ (§ 99.31(a)(9))។

- ឲ្យទៅភ្នាក់ងារផ្សេងៗ ដែលទាក់ទងនឹងសុខភាព ឬសុវត្ថិភាព ពេលមានអាសន្ន តាមច្បាប់ § 99.36។ (§ 99.31(a)(10)។

- ព័ត៌មានដែលសាលាបានជ្រើសរើសទុកជាមុនថាជា «ព័ត៌មានដែលមិនបណ្តាលឲ្យមានគ្រោះថ្នាក់» ប្រសិនបើតម្រូវការដែលពាក់ព័ន្ធក្រោមច្បាប់ § 99.37 ត្រូវតាមតម្រូវការ។ (§ 99.31(a)(11))។

- ឲ្យទៅអង្គការសង្គមកិច្ច ឬអ្នកតំណាងផ្សេងទៀត នៃទីភ្នាក់ងារសុខមាលភាពក្មេងក្នុងតំបន់ ឬរដ្ឋ អង្គការកុលសម្ព័ន្ធដែលត្រូវបានគេអនុញ្ញាតឱ្យយកគម្រោងផែនការរបស់សិស្ស នៅពេលដែលទីភ្នាក់ងារ ឬអង្គការនេះទទួលខុសត្រូវតាមច្បាប់រដ្ឋ ឬច្បាប់កុលសម្ព័ន្ធសម្រាប់ការថែរក្សា និងការពារសិស្ស ក្នុងការដាក់ក្មេងនៅកន្លែងចិញ្ចឹមថែទាំ។ (20 U.S.C. § 1232g(b)(1)(L))។

- ឲ្យទៅ លេខាធិការក្រសួងកសិកម្ម (Secretary of Agriculture) ឬអ្នកតំណាងដែលមានការអនុញ្ញាតពី សេវាកម្មអាហារ និងអាហារូបត្ថម្ភ (Food and Nutrition Service) សម្រាប់គោលបំណងនៃការរៀបចំកម្មវិធីត្រួតពិនិត្យ ការវាយតម្លៃ និងការវាស់វែងការអនុវត្ត នៃកម្មវិធីដែលបានអនុញ្ញាតក្រោម ច្បាប់ជាតិស្តីពីអាហារថ្ងៃត្រង់នៅសាលារីឆាត ប៊ី រូស្សិល្ល (Richard B. Russell National School Lunch Act) ឬ ច្បាប់អាហារូបត្ថម្ភក្មេងនៃឆ្នាំ ១៩៩៦ (Child Nutrition Act of 1996) ក្រោមល័ក្ខខ័ណ្ឌផ្សេងៗ។ ។ (20 U.S.C. § 1232g(b)(1)(K))។